## យុទ្ធសាស្ត្រទី ៤ : ការអភិវឌ្ឍសមត្ថភាពជំនាញបច្ចេក-ទេស និងវិជ្ជាជីវៈជូនប្រជាពលរដ្ឋ

គោលបំណងនៃយុទ្ធសាស្ត្រនេះ គឺផ្តល់ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈប្រកបដោយគុណភាព និងមានប្រសិទ្ធភាពខ្ពស់ ដែលអាចឆ្លើយតបបាន ទៅនឹងសេចក្តីត្រូវការទាំងក្នុង និងក្រៅប្រទេស ដើម្បីឈានដល់សម្រេចគោលដៅមួយ គឺបង្កើនប្រាក់ចំណូលលើកកំពស់កំរិតជីវភាពរបស់ប្រជាពលរដ្ឋ និងអភិវឌ្ឍប្រទេសជាតិ ។ ប៉ុន្តែបច្ចុប្បន្ននេះវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅមានបញ្ហាប្រឈមជាច្រើនរួមមាន បណ្តាញបណ្តុះបណ្តាលពុំទាន់ពង្រីកបានទូលំទូលាយគ្របដណ្តប់ដល់តំបន់ជនបទទូទាំងប្រទេសនៅឡើយ ។ រីឯគុណភាពបណ្តុះបណ្តាល មិនទាន់បានឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារទាំងស្រុងដោយការអភិវឌ្ឍស្តង់ដាជាតិសមត្ថភាព ការអភិវឌ្ឍប្រព័ន្ធព័ត៌មានទីផ្សារការងារ និងកម្មវិធីសិក្សានៅមានកំរិត ដោយរួមផ្សំជាមួយការរៀបចំប្រព័ន្ធ គ្រប់គ្រងមិនទាន់បានសុក្រឹត ។ល។ ហេតុនេះវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ មានគោលដៅគោលបំណង និងសកម្មភាពជាអាទិភាព ដូចខាងក្រោម :